*ប្រព័ន្ធការពារ និងការតស៊ូមតិរដ្ឋកាលីហ្វ័រនីញ៉ា*

# សន្លឹកការពិត ៖ សត្វសេវាកម្មនៅកន្លែងអាជីវកម្ម និងកន្លែងសាធារណៈ

*បោះពុម្ពក្នុងខែធ្នូ ឆ្នាំ 2020 #F114.06*

## សេចក្តីផ្តើម

Title II នៃ ADA (42 U.S.C. ផ្នែកទី 12131-12165) ហាមឃាត់មិនឲ្យមានការរើសអើងចំពោះអ្នកមានពិការភាពជាប់ខ្លួន ពីសំណាក់ "អង្គភាពសាធារណៈ" ។ Title III (42 U.S.C. ផ្នែកទី 12181-12189) ហាមឃាត់មិនឲ្យមានការរើសអើងចំពោះពិការភាពដោយ "ទីស្នាក់អាស្រ័យសាធារណៈ" ។ អង្គភាពសាធារណៈ គឺជាទីកន្លែងដែលប្រតិបត្តិការដោយរដ្ឋបាលរដ្ឋ ឬរដ្ឋបាលមូលដ្ឋាន មានដូចជាអាគាររដ្ឋាភិបាល មធ្យោបាយធ្វើដំណើរសាធារណៈ និងសួនច្បារសាធារណៈ ដែលនៅទីនេះគឺសំដៅលើពាក្យថា "ទីកន្លែងសាធារណៈ" ។ ការសម្រួលសាធារណៈ គឺជាទីកន្លែងរបស់អាជីវកម្មដែលបើកបម្រើសាធារណៈជន ដូចជាភោជនីយដ្ឋាន សណ្ឋាគារ រោងភាពយន្ត ហាងទំនិញ ការិយាល័យពេទ្យ និងមន្ទីរពេទ្យ ដែលនៅទីនេះ គឺសំដៅលើពាក្យថា "អាជីវកម្ម" ។ ក្រមអ៊ុនរូហ៍កាលីហ្វ័រនីញ៉ា (California's Unruh Act) (ក្រមរដ្ឋប្បវេណី វគ្គទី 51- 51.2 - Civil Code Sections 51- 51.2) ក្រមជនពិការ (Disabled Persons Act) (ក្រមរដ្ឋប្បវេណី វគ្គទី 54-55.32 - Civil Code Sections 54-55.32) និងក្រមរដ្ឋាភិបាល វគ្គទី 11135 (Government Code Section 11135) (សម្រាប់កម្មវិធីដែលប្រតិបត្តិការដោយរដ្ឋ ឬអាជីវកម្ម ដែលទទួលជំនួយហិរញ្ញវត្ថុពីរដ្ឋ) មានផ្តល់ជូនការការពារចំពោះជនពិការស្រដៀងគ្នា ។

ផ្នែកទី 504 នៃច្បាប់ស្តារនិតិសម្បទា  ឆ្នាំ  1973 (Rehabilitation Act of 1973) មានផ្តល់កិច្ចការពារស្រដៀងគ្នា សម្រាប់ទីភ្នាក់ងារសហព័ន្ធ ដូចជា សេវាកម្មប្រៃសនីយសហរដ្ឋអាមេរិក និងសម្រាប់កម្មវិធីរបស់រដ្ឋបាលរដ្ឋ និងរដ្ឋបាលមូលដ្ឋាន ព្រមទាំងអង្គការឯកជន បូករួមទាំងសាលារៀន និងមហាវិទ្យាល័យ ដែលទទួលជំនួយថវិកាពីសហព័ន្ធ ។ ការធ្វើដំណើរតាមយន្តហោះ គឺត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិរបស់ក្រុមហ៊ុនអាកាសចរណ៍ផ្ទាល់ ដែលយើងនឹងលើកយកមកពិភាក្សាខាងក្រោម។

ជនពិការ មិនមាន
សិទ្ធិនាំសត្វសម្រាប់ជួយលួងលោមអារម្មណ៍មកកាន់បរិវេណអាជីវកម្ម ឬបរិវេណសាធារណៈបានឡើយ។ សិទ្ធិនេះ
គឺអាចអនុវត្តបានចំពោះតែសត្វដែលគេបង្វឹកសម្រាប់ជួយសម្រួលដល់មនុស្សពិការតែប៉ុណ្ណោះ។ ដូច្នេះ បើអ្នកចង់ចូលក្នុងបរិវេណទាំងអស់នេះ
ប្រការសំខាន់គឺថាអ្នកត្រូវតែដឹងថា តើសត្វរបស់អ្នក
មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសត្វសម្រាប់ជួយសម្រួលដល់មនុស្សពិការដែរឬទេ។

## សិទ្ធិប្រើសត្វជួយសម្រួលដល់ជនពិការពេលចូលក្នុងបរិវេណអាជីវកម្ម ឬបរិវេណសាធារណៈ

## A. តើអ្វីជាសត្វសម្រាប់ជួយសម្រួលដល់មនុស្សពិការ?

"សត្វសេវាកម្ម"
គឺជាឆ្កែដែលត្រូវបានហ្វឹកហាត់សម្រាប់ជួយការងារមនុស្សមានពិការភាពជាប់ខ្លួនដែលមានដូចជាពិការរាងកាយ ពិការវិញ្ញាណ វិកលចរិក ពិការខួរក្បាល
ឬពិការផ្លូវចិត្តផ្សេងៗទៀត"។ បើទោះបីជានិយមន័យនៅទីនេះ
គឺនិយាយសំដៅតែចំពោះសត្វឆ្កែក៏ដោយ ក៏បទបញ្ញត្តិសហព័ន្ធ
អនុញ្ញាតឲ្យប្រើសេះតូចៗសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន
នៅក្នុងបរិវេណអាជីវកម្ម និងកន្លែងសាធារណៈ បានផងដែរ បើសត្វប្រភេទនេះ
បានទទួលការបង្វឹកឲ្យចេះជួយការងារជនមានពិការភាពជាប់ខ្លួន ហើយអាចប្រើឲ្យបានសមហេតុផល។ សត្វមួយ
មិនអាចចាត់ទុកថាជាសត្វសម្រាប់ជួយសម្រួលដល់ជនមានពិការភាពជាប់ខ្លួនបានទេ បើវត្តមានរបស់វាគឺគ្រាន់តែមានប្រយោជន៍ចំពោះជនដែល
មានពិការភាពជាប់ខ្លួននោះ។

ឧទាហរណ៍អំពីកិច្ចការដែលសត្វជួយសម្រួលដល់ជនមានពិការភាពជាប់ខ្លួនធ្វើ គឺ៖ ជួយបើកភ្លើង ជួយយករបស់ ជួយទប់កុំឲ្យដួល ជួយរំញោចកាយវិញ្ញាណ
និងការព្យាបាលដោយការសង្កត់ធ្ងន់ៗ/ជិះពីលើជនមានពិការភាពជាប់ខ្លួន។
បើសិនជាអ្វីដែលត្រូវធ្វើ គឺមិនមែនជាការផ្តល់សញ្ញាពីម្ចាស់វា ការដឹង
និងការឆ្លើយតបរបស់ឆ្កែក្នុងស្ថានភាពបែបនេះ
គេហៅវាថាជា*ការងារ*របស់ឆ្កែសម្រាប់ជួយ មនុស្ស។
ឧទាហរណ៍អំពីការងារដែលឆ្កែធ្វើដើម្បីជួយជនមានពិការភាពជាប់ខ្លួន
មានជាអាទិ៍ (តែក៏មិនកំណត់តែចំពោះ) ការបង្ការ ឬការបង្អាក់សកម្មភាពដែលធ្វើភ្លាមៗតាមសន្ទុះចិត្ត ឬបង្អាក់សកម្មភាពដែលបង្កមហន្តរាយ
ជួយរំឭកម្ចាស់វាឲ្យលេបថ្នាំ និងនាំម្ចាស់វាដែលមិនដឹងអី (វង្វេងស្មារតី)
ឲ្យគេចផុតពីស្ថានការណ៍គ្រោះថ្នាក់។ បើនិយាយពីទិដ្ឋភាពច្បាប់វិញ
គឺមិនមានភាពតម្រូវជាក់លាក់ចំពោះបរិមាណ
ឬប្រភេទការងារដែលសត្វសម្រាប់ជួយមនុស្សត្រូវតែធ្វើ
ដើម្បីជួយជនមានពិការភាពជាប់ខ្លួនឡើយ។

## B. តើខ្ញុំអាចបង្ហាញឲ្យគេដឹងយ៉ាងដូចម្តេចថា ឆ្កែរបស់ខ្ញុំជាឆ្កែសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន?

អ្វីដែលជាភាពតម្រូវតែមួយមុខពីច្បាប់គឺថា ឆ្កែនោះត្រូវបានទទួលការបង្វឹកដោយផ្ទាល់ សម្រាប់ជួយជនមានពិការភាព ។ សត្វសម្រាប់ជួយជនមានពិការភាព អាចត្រូវបានបង្វឹកដោយអ្នកឯកទេស មិត្តភ័ក្តិ សមាជិកគ្រួសារ ឬជនដែលមានពិការភាពជាប់ខ្លួនតែម្តង។ ក្រោមច្បាប់ ADA ឆ្កែសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន គឺមិនចាំបាច់ចុះបញ្ជីជាសត្វសម្រាប់ជួយជនដែលមានពិការភាពជាប់ខ្លួន ឬត្រូវពាក់ស្លាកពិសេស ឬពាក់អាវសម្រាប់សម្គាល់ថាវាជាសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួនឡើយ ។ ច្បាប់របស់រដ្ឋកាលីហ្វ័រនីញ៉ា អនុញ្ញាតឲ្យនាយកដ្ឋានប្រចាំមូលដ្ឋានផ្នែកគ្រប់គ្រងសត្វ ជាអ្នកចេញស្លាកសម្រាប់សម្គាល់ ដល់អ្នកបង្វឹកឆ្កែសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ បើឆ្កែនោះមិនបានទទួលការបង្វឹកឲ្យធ្វើជាសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួនទេ គឺមិនត្រូវពាក់ស្លាកឲ្យវាឡើយ ហើយមិនត្រូវកំណត់ថា ក្រោមច្បាប់ដែលមានស្រាប់ សត្វចិញ្ចឹមគឺជាសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួននោះទេ ។

លុះត្រាតែមានមូលហេតុដែលគួរឲ្យជឿថា សត្វណាមួយសម្រាប់ជួយមនុស្សមានពិការភាពជាប់ខ្លួន អាចបង្កភាពប្រឈមចំពោះសុខភាព ឬសុវត្ថិភាពសាធារណៈ ទើបបុគ្គលិកអាជីវកម្ម ឬមន្ត្រីរដ្ឋាភិបាល អាចសួរបានតែពីរសំណួរ ដើម្បីបញ្ជាក់ថាតើសត្វនោះ ជាសត្វដែលបានបង្វឹកសម្រាប់ជួយជនមានពិការភាពជាប់ខ្លួនដែរឬទេ ៖ 1) តើចាំបាច់ត្រូវការយកសត្វនេះមកតាម ដោយសារតែម្ចាស់វាមានពិការមែនទេ? និង 2) តើសត្វនេះ ត្រូវបានបង្វឹកឲ្យជួយធ្វើអ្វីខ្លះ? ក្រោមច្បាប់របស់រដ្ឋកាលីហ្វ័រនីញ៉ា ការធ្វើឲ្យគេឯងយល់ខុសថា ឆ្កែណាមួយជាឆ្កែដែលបានបង្វឹកសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន គឺជាបទល្មើសមជ្ឈឹម ដែលត្រូវទទួលទោសជាប់ពន្ធនាគាររហូតដល់ប្រាំមួយខែ និង/ឬត្រូវពិន័យជាប្រាក់រហូតដល់ $1,000 (ច្បាប់ព្រហ្មទណ្ឌ ផ្នែកទី 365.7(a) - Penal Code Section 365.7(a)) ។

## C. តើនៅពេលណាដែលគេអាចបដិសេធមិនឲ្យសត្វសម្រាប់ជួយខ្ញុំចូលក្នុងបរិវេណអាជីវកម្ម ឬទីកន្លែងសាធារណៈ?

ទីកន្លែងអាជីវកម្ម និងទីកន្លែងសាធារណៈ មិនត្រូវបានតម្រូវថា ត្រូវតែឲ្យសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន ដែលបង្កការគម្រាមកំហែងដោយផ្ទាល់ដល់អ្នកដទៃ

ដែលមិនបានស្ថិតក្រោមការថែទាំ និងគ្រប់គ្រងពីម្ចាស់
ឬដែលអាចធ្វើឲ្យខូចលក្ខណៈដើមនៃរបស់របរ សេវាកម្ម ឬកម្មវិធី
ដែលផ្តល់ដោយអាជីវកម្ម ឬអង្គភាពរដ្ឋ ចូលទៅឡើយ។

"ការគម្រាមកំហែងដោយផ្ទាល់" ជាហានិភ័យធ្ងន់ធ្ងរចំពោះសុខភាព
ឬសុវត្ថិភាពអ្នកដទៃ
ដែលមិនអាចបំបាត់បានដោយការកែតម្រូវគោលនយោបាយ ការអនុវត្ត
ឬទម្រង់ការ ឬមិនអាចបំបាត់បានដោយការផ្តល់ជំនួយ ឬសេវាកម្មគាំទ្រ។
ឧទាហរណ៍ ឆ្កែដែលខាំគេដោយមិនដឹងរឿង
អាចជាឆ្កែដែលបង្កការគម្រាមកំហែងដោយផ្ទាល់ចំពោះអ្នកដទៃ។ អ្វីដែល
អង្គភាពត្រូវធ្វើ គឺការកំណត់មើលថា
តើសត្វនោះជាសត្វអាចបង្កការគម្រាមកំហែងដោយផ្ទាល់ដល់អ្នកដទៃឬទេ

ការវាយតម្លៃតម្រូវតាមលក្ខណៈបុគ្គល យោងតាមការវិនិច្ឆ័យប្រកប
ដោយហេតុផលសមរម្យ ដែលសំអាងលើ ចំណេះដឹងវេជ្ជសាស្ត្របច្ចុប្បន្ន
ឬសំអាងលើភស្តុតាងជាសច្ចានុម័តិដែលអាចរកបាន។ ការ
វាយតម្លៃត្រូវមើលចំពោះ៖ ស្ថានភាព រយៈពេល និងភាពធ្ងន់ធ្ងរនៃហានិភ័យ
ភាគរយដែលថា សក្តានុពលនៃគ្រោះថ្នាក់អាចកើតឡើងបាន ហើយថាតើ
បើមានការសម្រួលសមហេតុផល ចំពោះគោលនយោបាយ ការអនុវត្ត
ឬទម្រង់ការ ឬការផ្តល់ជូនជំនួយ ឬសេវាកម្មគាំទ្រ
អាចនឹងលុបបំបាត់ហានិភ័យបានដែរឬទេ។

ការមិនឲ្យឆ្កែសម្រាប់ជួយជនមានពិការភាពជាប់ខ្លួនចូលក្នុងបរិវេណបែបនេះ
ដោយសំអាងលើការបង្កការគម្រាមកំហែងដោយផ្ទាល់
គឺត្រូវគិតអំពីអាកប្បកិរិយាពិតប្រាកដនៃសត្វនោះ គឺមិនត្រូវយកការសន្និដ្ឋាន
ឬទម្លាប់ដែលថាតើសត្វនោះ ឬពូជសត្វនោះ អាចបង្កហេតុការណ៍បែបនេះ
ឬបែបនោះឡើយ។

សត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន ជានិច្ចកាល
ត្រូវស្ថិតក្រោមការមើលថែទាំ និងគ្រប់គ្រងពីម្ចាស់វា
ឬពីអ្នកណាម្នាក់ដែលម្ចាស់វាចាត់ឲ្យជួយ។
គេអាចស្នើសុំជនមានពិការភាពជាប់ខ្លួន មិនឲ្យយកសត្វសម្រាប់ជួយ
ចូលក្នុងបរិវេណខាងលើ បើសត្វនោះមិនអាចគ្រប់គ្រងបាន ហើយម្ចាស់សត្វនោះ
មិនបានប្រឹងប្រែងដើម្បីគ្រប់គ្រងសត្វនោះ ឬសត្វនោះដុះនោមផ្តេសផ្តាស។
ការទទួលខុសត្រូវក្នុងការថែទាំសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន
គឺមិនត្រូវធ្លាក់លើម្ចាស់អាជីវកម្ម ឬអង្គភាពរដ្ឋ
ដែលអនុញ្ញាតឲ្យជនពិការចូលទៅទីនោះឡើយ។

ជាទូទៅ សត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន ត្រូវមានបង្ហៀរ
ខ្សែចងសម្រាប់ដឹក ឬខ្សែចងផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ
បើម្ចាស់សត្វនោះមិនអាចប្រើបង្ហៀរ ខ្សែចងដឹក ឬខ្សែចំណងផ្សេងទៀតបាន
ដោយសារពិការភាព ឬក៏បើការប្រើខ្សែចង
វាបណ្តាលឲ្យសត្វមានការរំខានចំពោះសុវត្ថិភាព

បង្កការរំខានចំពោះប្រសិទ្ធិភាពបំពេញការងារ របស់សត្វស្រាប់ជួយជនពិការ ម្ចាស់សត្វនោះត្រូវប្រើមធ្យោបាយផ្សេងទៀត សម្រាប់គ្រប់គ្រងសត្វនោះ។

គេអាចបដិសេធមិនឲ្យសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន ចូលក្នុងបរិវេណអាជីវកម្ម និងអគាររដ្ឋបាន ប្រសិនបើការអនុញ្ញាតិឲ្យចូលអាចធ្វើឲ្យមានការកែប្រែលក្ខណៈជាមូលដ្ឋានរបស់ឥវ៉ាន់ សេវាកម្ម ឬកម្មវិធី ដែលមានផ្តល់ជូននៅក្នុងបរិវេណនោះ។ ឧទាហរណ៍ គេអាចរឹតត្បិតចំពោះសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន ក្នុងការចូលសួនសត្វ ដែលសត្វនៅក្នុងសួននោះ ជាធម្មជាតិគឺជាសត្វដែលឆ្កែចូលចិត្តស៊ី ឬជាសត្វដែលចូលចិត្តស៊ីឆ្កែ ឬក៏បើសិនជាមានឆ្កែចូលក្នុងសួន អាចបង្កការរំខានចំពោះសត្វទាំងអស់ក្នុងសួន។

## D. តើខ្ញុំអាចយកសត្វសម្រាប់ជួយខ្ញុំចូលក្នុងមន្ទីរពេទ្យបានទេ?

មន្ទីរពេទ្យ និងកន្លែងថែទាំសុខភាពផ្សេងទៀត គឺត្រូវគេចាត់ទុកដូចជាកន្លែងអាជីវកម្ម និងកន្លែងសាធារណៈដទៃទៀតដែរ សម្រាប់ការឲ្យ ឬមិនឲ្យសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួនចូល។ សត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន ត្រូវគេអនុញ្ញាតឲ្យចូលបានគ្រប់ទិសទីរបស់មន្ទីរពេទ្យ ដែលបុគ្គលិកពេទ្យ អ្នកជម្ងឺ និងភ្ញៀវអាចចូលបាន។ ត្រង់នេះគឺរួមទាំងបន្ទប់អ្នកជម្ងឺ និងទីកន្លែងសាធារណៈដទៃទៀតសម្រាប់អ្នកជម្ងឺសម្រាកពេទ្យ និងអ្នកជម្ងឺមិនសម្រាកពេទ្យផ្នែករោគចិត្ត គឺបូករួមទាំងកន្លែងអ្នកជម្ងឺផ្លូវចិត្តដែលត្រូវចាក់សោរផងដែរ។ អ្នកជម្ងឺខ្លួនឯងត្រូវមានលទ្ធភាពមើលថែទាំសត្វរបស់ខ្លួន ឬក៏ចាត់ចែងឲ្យអ្នកណាម្នាក់ជួយមើលថែទាំវា បើចាំបាច់។ សត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន អាចមិនត្រូវអនុញ្ញាតឲ្យចូលបរិវេណមួយចំនួនក្នុងមន្ទីរពេទ្យដោយសេរីដែលជាកន្លែងការពារការឆ្លងរោគ ដូចជា បន្ទប់វះកាត់ និងកន្លែងព្យាបាលអ្នកជម្ងឺរលាកភ្លើង។ នៅមន្ទីរពេទ្យ គឺដូចគ្នានឹងនៅកន្លែងអាជីវកម្ម នឹងទីន្លែងផ្សេងទៀតរបស់រដ្ឋាភិបាលដែរ គឺនៅពេលដែលបុគ្គលិកសុខភាព មិនមានភាពប្រាកដថា សត្វនោះជាសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួន ពួកគេនឹងសួរទៅម្ចាស់វាថា តើវាជាសត្វសម្រាប់ជួយជនពិការមែនទេ តែគេអាចមិនតម្រូវឲ្យមានលិខិតបញ្ជាក់ ឬត្រូវការសំណុំឯកសារផ្សេងៗ ដើម្បីបញ្ជាក់ថាវាជាសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួនឡើយ។

## E. តើខ្ញុំអាចយកសត្វសម្រាប់ជួយខ្ញុំ ឡើងយន្តហោះជាមួយគ្នាបានទេ?

អាចយកបាន ដរាបណាសត្វផ្តល់សេវាកម្មនោះគឺជាសត្វឆ្កែ។ ការធ្វើដំណើរតាមយន្តហោះ ត្រូវស្ថិតក្រោមការគ្រប់គ្រងនៃច្បាប់សហព័ន្ធស្តីអំពីការទទួលបានសេវាកម្មធ្វើដំណើរតាមយន្តហោះ (ACAA, Air Carrier Access Act) (49 U.S.C. ផ្នែកទី 41705) និងការអនុវត្តន្តវបញ្ញត្តិ 14 C.F.R.របស់ខ្លួន ផ្នែកទី 382។ ក្រសួងគមនាគមន៍សហរដ្ឋអាមេរិក (DOT, Department of Transportation) បានចេញវិធានចុងក្រោយចំពោះបទបញ្ញត្តិ ACCA ចំពោះការដឹកជញ្ជូនសត្វផ្តល់សេវាកម្ម

ដែលចូលជាធរមាននៅថ្ងៃទី 4 ខែមករា ឆ្នាំ 2021 ។ នៅមុនការធ្វើវិសោធនកម្ម ជនមានពិការភាពជាប់ខ្លួន អាចយកសត្វសម្រាប់ផ្តល់សេវាកម្ម ឬសត្វសម្រាប់លួងលោមចិត្ត ជិះយន្តហោះជាមួយបាន ។ ចំពោះវិធានថ្មីនេះ គឺអនុញ្ញាតឲ្យយកបានតែសត្វសម្រាប់ផ្តល់សេវាកម្ម ចំពោះមនុស្សដែលមានពិការភាពរាងកាយ និង/ឬពិការភាពផ្លូវចិត្តជាប់នឹងខ្លួនប៉ុណ្ណោះ ។ សត្វសម្រាប់ផ្តល់សេវាកម្មត្រូវគេកំណត់ថាជាសត្វឆ្កែ ដោយមិនគិតថាជាឆ្កែពូជ ឬប្រភេទអ្វីឡើយ ហើយជាឆ្កែដែលត្រូវបានគេបង្ហឹកដោយផ្ទាល់សម្រាប់ធ្វើការ ឬបំពេញភារកិច្ចសម្រាប់ជនមានពិការភាពជាប់ខ្លួន ដូចជាពិការភាពរាងកាយ អារម្មណ៍ ផ្លូវចិត្ត សតិប្រាជ្ញា ឬពិការភាពផ្លូវចិត្តផ្សេងទៀត ដែលមានលក្ខណៈសម្បត្តិអាចប្រើសត្វបែបនេះបាន ។

## សេចក្តីសង្ខេបនៃការផ្តល់ជូន ៖

- ក្រុមហ៊ុនអាកាសចរណ៍ អាចស្នើសុំសំណៅក្រដាស ឬសំណៅអេឡិចត្រូនិកដែលពេញលេញរបស់ក្រសួងនូវ "បែបបទស្នើសុំដឹកសត្វសេវាកម្មតាមយន្តហោះរបស់ក្រសួងគមនាគមន៍ - U.S. Department of Transportation Service Animal Air Transportation Form" (សូមឆែកមើលវិបសៃត៍ក្រុមហ៊ុនអាកាសចរណ៍របស់អ្នក ដើម្បីរកមើលបែបបទដែលអាចបំពេញបាន) ដែលជាលក្ខ័ណ្ឌនៃការធ្វើដំណើរ ចំនួន 48 ម៉ោងមុនការចេញដំណើរ ចំពោះការកក់កៅអីសម្រាប់អ្នកដំណើរ ដែលបានធ្វើឡើងមុនគ្រានោះ

- កំណត់ចំនួនសត្វសេវាកម្ម សម្រាប់ធ្វើដំណើរជាមួយមនុស្សម្នាក់ ត្រឹម 2 ក្បាលជាអតិបរមា ហើយសត្វនោះត្រូវបំពាក់បង្ហៀរ ចងខ្សែបណ្តើរ ឬខ្សែចងធម្មតា ពេលមកដល់ព្រលានយន្តហោះ និងពេលនៅលើយន្តហោះ ។ ក្រុមហ៊ុនអាកាសចរណ៍ ក៏អាចតម្រូវឲ្យសត្វឆ្កែនោះ អង្គុយលើភ្លៅអ្នកដំណើរ ឬអង្គុយត្រង់ប្រឡោះដាក់ជើងអ្នកដំណើរផងដែរ ។ ច្បាប់មិនអនុញ្ញាតឲ្យក្រុមហ៊ុនអាកាសចរណ៍ បដិសេធមិនដឹកសត្វសេវាកម្ម ដោយសារពូជ ឬទំហំឡើយ

- ចំពោះអ្នកដំណើរត្រូវការយកសត្វសេវាកម្មតាមខ្លួន ដែលត្រូវធ្វើដំណើរចំនួន 8 ម៉ោង ឬយូរជាងនេះ គឺត្រូវតែមានការបញ្ជាក់ថា សត្វសេវាកម្មរបស់ខ្លួន នឹងមិនជុះអាចម៍នោមផ្តេសផ្តាស ឬចេះជុះអាចម៍នោមប្រកបដោយអនាម័យ ដោយការដាក់ជូននូវសំណៅឯកសារពេញលេញជាក្រដាស ឬជាទម្រង់អេឡិចត្រូនិក របស់ក្រសួង "លិខិតបញ្ជាក់សត្វសម្រាប់ជួយជនពិការ របស់ក្រសួងសហរដ្ឋអាមេរិក ផ្នែកសេវាកម្មគមនាគមន៍ - (U.S. Department of Transportation Service Animal Relief Attestation)" (សូមឆែកមើលវិបសៃត៍ក្រុមហ៊ុនអាកាសចរណ៍របស់អ្នក ដើម្បីរកមើលបែបបទដែលអាចបំពេញបាន) និង

- អ្នកដំណើរអាចចុះឈ្មោះធ្វើដំណើរតាមអនឡាញ ហើយមិនត្រូវបានតម្រូវឲ្យចុះឈ្មោះធ្វើដំណើរឡើងវិញនៅព្រលានយន្តហោះទេ ។

## F. តើអង្គភាពអាជីវកម្ម ឬអង្គភាពរដ្ឋាភិបាល អាចគិតថ្លៃសម្រាប់ការនាំសត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួនចូលក្នុងទីកន្លែងរបស់ពួកគេដែរឬទេ?

អង្គភាពអាជីវកម្ម ឬអង្គភាពរដ្ឋាភិបាល មិនអាចតម្រូវឲ្យជនមានពិការភាពជាប់ខ្លួនកក់ថ្លៃ ឬបង់ថ្លៃបន្ថែម ដើម្បីយកសត្វសម្រាប់ជួយខ្លួនចូលក្នុងទីកន្លែងទាំងនោះឡើយ បើទោះបីជាពួកគេមានគោលនយោបាយឲ្យបង់ថ្លៃសម្រាប់នាំសត្វចិញ្ចឹមចូលក្នុងទីកន្លែងទាំងអស់នោះក៏ដោយចុះ ។ បើអាជីវកម្មសាធារណៈ ឬអង្គភាពសាធារណៈ ទារថ្លៃធម្មតាពីភ្ញៀវរបស់ខ្លួនចំពោះការខូចខាតចំពោះបរិវេណរបស់ពួកគេ គឺពួកគេអាចទារថ្លៃខូចខាតពីម្ចាស់សត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួននេះសម្រាប់ការខូចខាតស្រដៀងគ្នា ។

## G. តើខ្ញុំអាចយកសត្វសម្រាប់ជួយខ្ញុំ ដែលកំពុងស្ថិតក្នុងការបង្ហឹកចូលក្នុងបរិវេណអាជីវកម្ម ឬទីកន្លែងសាធារណៈបានដែរឬទេ?

សត្វសម្រាប់ជួយជនមានពិការភាពជាប់ខ្លួនដែលកំពុងស្ថិតក្នុងការហ្វឹកហាត់ គឺមិនបានស្ថិតក្រោមការគ្របដណ្តប់របស់ច្បាប់ ADA ឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ច្បាប់ជនពិការរដ្ឋកាលីហ្វ័រនីញ៉ា (California Disabled Persons Act) អនុញ្ញាតឲ្យជនមានពិការភាពជាប់ខ្លួន និងអ្នកបង្ហឹកសត្វសម្រាប់ជួយជនពិការ អាចយកសត្វឆ្កែចូលក្នុងទីកន្លែងសាធារណៈសម្រាប់គោលបំណងបង្ហឹកសត្វនោះឲ្យចេះផ្តល់ជំនួយពាក់ព័ន្ធនឹងពិការភាព ដល់ជនមានពិការភាពជាប់ខ្លួន ។ ត្រង់នេះគឺរួមបញ្ចូលទាំងបរិវេណអាជីវកម្មមធ្យោបាយធ្វើដំណើរសាធារណៈ និងឯកជន ការសម្រួលផ្នែកគេហដ្ឋាននិងទីកន្លែងផ្សេងទៀតដែលមនុស្សម្នាអាចចេញចូលបានជាសាធារណៈ ។ ឆ្កែដែលត្រូវចូលក្នុងកន្លែងទាំងអស់នោះ ត្រូវមានចងខ្សែ ហើយត្រូវពាក់ស្លាកដែលខោនធីជាអ្នកចេញឲ្យ សម្រាប់សម្គាល់ថាឆ្កែនោះជាឆ្កែសម្រាប់ជួយជនពិការ ឬជាឆ្កែសម្រាប់ជំនួយក្នុងការបង្ហឹក ។ ម្ចាស់ឆ្កែគឺជាអ្នកទទួលខុសត្រូវចំពោះការខូចខាតនានា ដែលបណ្តាលពីឆ្កែចំពោះទីកន្លែង ឬអគារទាំងអស់នោះ ។

## ការតវ៉ា និងបណ្តឹងផ្លូវច្បាប់

បើអ្នកជឿថា អ្នកបានទទួលការរើសអើងយ៉ាងអយុត្តិធម៌ពីអង្គភាពអាជីវកម្ម ឬអង្គភាពសាធារណៈ ដោយសារតែសត្វសម្រាប់ជួយអ្នក អ្នកអាចដាក់ពាក្យតវ៉ាមកកាន់ក្រសួងយុត្តិធម៌ (DOJ, Department of Justice) ។ បើការប្តឹងតវ៉ា គឺជាការប្តឹងចំពោះរដ្ឋាភិបាល ឬប្តឹងចំពោះអង្គភាពឯកជនដែលបានទទួលជំនួយហិរញ្ញវត្ថុពីសហព័ន្ធ គឺបណ្តឹងនោះត្រូវតែមកដល់ដៃក្រសួងឲ្យបានក្នុងរវាង 180 ថ្ងៃ

គិតចាប់ពីថ្ងៃដែលហេតុការណ៍ប្រព្រឹត្តិរើសអើងបានកើតឡើង
(នៅពេលដែលបញ្ហានោះបានកើតឡើង)។
ចំពោះការដាក់ពាក្យប្តឹងតវ៉ាប្រឆាំងនឹងអង្គភាពអាជីវកម្មដែលមិនបានទទួលជំនួយហិរញ្ញវត្ថុពីសហព័ន្ធ ក្រោមច្បាប់ ADA គឺមិនមានការផុតថ្ងៃកំណត់ឡើយ តែវាជាការប្រសើរ
បើអ្នកអាចដាក់ពាក្យបណ្តឹងឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។
សម្រាប់ព័ត៌មានបន្ថែមអំពីការដាក់ពាក្យបណ្តឹងមកកាន់ក្រសួងយុត្តិធម៌
(Department of Justice) គឺមាននៅឯ
https://www.ada.gov/filing_complaint.htm
ឬតាមរយៈលេខទូរស័ព្ទផ្តល់ព័ត៌មានរបស់ ADA (ADA Information Line)
តាមលេខ (800) 514-0301 (សម្រាប់សម្លេង) លេខ (800) 514-0383
សម្រាប់អ្នកប្រើ TTY)។

អ្នកក៏អាចដាក់ពាក្យបណ្តឹងរដ្ឋបាល រាល់ការរើសអើងបណ្តាលពីពិការភាព
ដែលពាក់ព័ន្ធនឹងសត្វឆ្កែសម្រាប់ផ្តល់សេវាកម្ម
ឬសត្វសម្រាប់គាំទ្រផ្នែកអារម្មណ៍របស់អ្នក ក្រោមច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា
ដោយប្តឹងមកកាន់ក្រសួងកាលីហ្វ័រនីញ៉ាផ្នែកយុត្តិធម៌ការងារ និងគេហកិច្ច
(DFEH, California Department of Fair Employment and Housing)
ឲ្យបានក្នុងរវាងមួយឆ្នាំ
ដោយគិតពីថ្ងៃចុងក្រោយនៃការប្រព្រឹត្តិរើសអើងបានកើតឡើង។
ព័ត៌មានបន្ថែម ពីរបៀបដាក់ពាក្យបណ្តឹងជាមួយនឹង DFEH គឺមាននៅឯ
https://www.dfeh.ca.gov/complaintprocess/ ឬសូមហៅទូរស័ព្ទមកលេខ
(800) 884-1684 (សម្លេង) ឬលេខ (800) 700-2320 (TTY)។

ក្រសួង បែបបទរបស់ក្រសួង សម្រាប់បំពេញបណ្តឹងបែបបទពាក់ព័ន្ធនឹងបញ្ហាពិការភាព ជាមួយនឹងក្រុមហ៊ុនអាកាសចរណ៍ មានផ្តល់ជូននៅឯ៖
http://www.dot.gov/airconsumer/file-consumer-complaint.

ជាជម្រើស ឬបន្ថែមពីលើការដាក់ពាក្យបណ្តឹងមកកាន់ DOJ ឬ DFEH
គឺថាអ្នកអាចដាក់បណ្តឹងផ្លូវច្បាប់មកកាន់តុលាការរដ្ឋ ឬតុលាការសហព័ន្ធ
សម្រាប់បង្គាប់ និងការទារសំណងក្រោមច្បាប់សហព័ន្ធ ឬច្បាប់រដ្ឋ។
ការទាមទារសំណងការខូចខាតជាប្រាក់ អាចមាននៅក្រោមច្បាប់រដ្ឋ
ដោយបូករួមទាំងអាជ្ញាយុកាលការខូចខាតជាកម្រិតអប្បរមាចំនួន $4,000
ក្នុងមួយហេតុការណ៍នៃការប្រព្រឹត្តរើសអើង។ ក្រមរដ្ឋប្បវេណី §52 (Civil Code
§52)។ បណ្តឹងតាមផ្លូវច្បាប់ ត្រូវតែធ្វើឡើងក្នុងរវាងពីរឆ្នាំ
ក្រោយពេលហេតុការណ៍ប្រព្រឹត្តិរើសអើងបានកើតឡើង។

បើអ្នកទាមទារសំណងខូចខាតជាទឹកប្រាក់មានចំនួនតិចជាង $10,000 គឺអ្នកមានជម្រើសមួយទៀត ក្នុងការប្តឹងពីបទប្រព្រឹត្តរើសអើងទៅកាន់តុលាការទទួលបណ្តឹងលើសំណងតូចតាច (Small Claims Court)។ អាជ្ញាយុកាលនៃដែនកំណត់ចំពោះការដាក់ពាក្យប្តឹង ដែលបានបង្ហាញខាងលើ គឺអាចប្រើបាន។ អ្នកមិនអាចរកមេធាវីសម្រាប់ជួយបានឡើយ បើអ្នកសម្រេចដាក់ពាក្យបណ្តឹងទៅកាន់តុលាការទទួលបណ្តឹងលើសំណងតូចតាច (Small Claims Court)។ នេះជាតំណភ្ជាប់ទៅកាន់ឯកសារបោះពុម្ពផ្សាយរបស់អង្គការ Disability Rights

California ដែលពន្យល់អំពីដំណើរការនៃការប្រើបណ្ដឹងទាមទារសំណងតិចតួច ចំពោះសំណុំរឿងការប្រព្រឹត្តរើសអើង៖
http://www.disabilityrightsca.org/pubs/520601.pdf.
លើសពីនេះ ច្បាប់ទាមទារសំណងខូចខាតរដ្ឋប្បវេណី (Government Tort Claims Act) របស់រដ្ឋាភិបាលតម្រូវឲ្យការទាមទារសំណងខូចខាតស៊ីវិលពីរដ្ឋាភិបាល ត្រូវដាក់ប្ដឹងឲ្យបានក្នុងរវាងប្រាំមួយខែគិតពីពេលដែលហេតុការណ៍ប្រព្រឹត្តរើសអើងបានកើតឡើង នៅមុនពេលធ្វើបណ្ដឹងតាមច្បាប់ទាមទារការខូចខាតជាទឹកប្រាក់ពីរដ្ឋ ឬអង្គភាពរដ្ឋបាលមូលដ្ឋាន។
ចំពោះព័ត៌មានបន្ថែមអំពីការទារសំណងកំហុសស៊ីវិល គឺមាននៅឯ http://www.disabilityrightsca.org/pubs/522901.htm សូមកត់ចំណាំថា វិបសៃត៍នេះភ្ជាប់ទៅកាន់សំណុំបែបបទសម្រាប់ប្ដឹងទារសំណងពីរដ្ឋ ឬពីភ្នាក់ងាររដ្ឋ ឬនិយជិករដ្ឋ ដែលអាចមិនត្រូវចំពោះសំណុំរឿងរបស់អ្នក។ អង្គភាពរដ្ឋដទៃទៀត អាចមានសំណុំបែបបទទាមទារសំណងខូចខាតរដ្ឋប្បវេណីនៅតាមវិបសៃត៍ របស់ពួកគេផ្ទាល់។ បើអ្នកមានបំណងធ្វើការប្ដឹងវិវាទ សូមពិភាក្សាជាមួយមេធាវីជាបន្ទាន់។

---

យើងខ្ញុំចង់ស្ដាប់យោបល់អ្នក! សូមជួយបំពេញសំណួរសម្រង់មតិខាងក្រោម ស្ដីអំពីការបោះពុម្ពផ្សាយរបស់យើងខ្ញុំ
ហើយប្រាប់ឲ្យយើងខ្ញុំបានដឹងពីគុណភាពការងាររបស់យើងខ្ញុំ! [ចូលរួមការស្ទង់មតិ]

# ទទួលជំនួយ

បើអ្នកជាបុគ្គល សមាជិកគ្រួសារ ឬតស៊ូមតិដើម្បីនរណាម្នាក់ ដែលមានពិការភាពជាប់ខ្លួន ហើយមានសំណួរអំពីសិទ្ធិផ្លូវច្បាប់ ពាក់ព័ន្ធនឹងពិការភាពជាប់ខ្លួនអ្នក សូមហៅទូរស័ព្ទទៅលេខ ៖

**1-800-776-5746**
ឬបើប្រើ TTY សូមហៅទៅលេខ ៖ 1-800-719-5798
មានផ្ដល់សេវាកម្មជូនពីថ្ងៃ ច-សុ ម៉ 9 ព្រឹក - ម៉ 4 ល្ងាច

*អង្គការ Disability Rights California បានទទួលថវិកាឧបត្ថម្ភពីប្រភពផ្ដល់ជំនួយផ្សេងៗ សម្រាប់បញ្ជីលម្អិតនៃម្ចាស់ជំនួយ សូមទស្សនាគេហទំព័រ*
http://www.disabilityrightsca.org/Documents/Documents/ListofGrantsAndContracts.html.